# ការសម្ភាសរបស់អ្នកមីង ធូ តន់

**កៈ អ្នកធ្វើការសម្ភាស មាសចិន្តាពិសី ខៈ អ្នកដែរគេសម្ភាស ធូតន់**

ខៈ ព្រឹកឡើងយកកូនទៅចោលនៅសាលារល់ល្ងាចបានយកមកផ្ទះវិញ ហេតុអីក៏អ្នកដឹកនយើងនេះមិនព្រមធ្វើយ៉ាងណា អោយមានប្រាក់ខែពេញ ហើយពេលដែរគេជម្លៀសនិងខ្ញុំទៅឯភ្នំពេញហើយ តែមុនជិតសិនប្រាំណាគេជម្លៀសអ្នកស្រុកដែរនៅឯនិងគេជម្លៀសយកទៅក្រៅអស់ហើយ ចេញទៅក្រៅស្រុកអស់ចឹងទៅ ដល់ពេលប៉ុលពតវាយមែនទែន បានជម្លៀសអ្នកស្រុកនិងទៅនៅក្នុងព្រៃតែម្តង ហើយក្មួយកុំសួរថាស្លាប់ប៉ុន្មានរស់ប៉ុន្មានអត់មានបានដឹងទេ ព្រោះអ្នកខ្លះគេដាច់ពូជហើយប្រាំពីរប្រាំបីនាក់ទៅទាំងអស់ស្វាត់ភូមិ ហើយមកដល់កប្រាំនេះមួយសារទៀត គឺចង់អស់តែម្តងប្រុសៗឥឡូវសំបូរតែស្រីម៉េម៉ាយទេ ម៉េម៉ាយដប់នាក់មិនទាន់មានប្រុសមួយនាក់ផង ជំនាន់អ៊ុំទេណាជំនាន់គេក្រោយនេះអត់អីទេ មើលគ្រួសាររបស់អ៊ុំនេះដឹងជាស្លាប់ប៉ុន្មាននាក់ទេ មើលអាជឹមមួយ ជន់មួយកូនបីប្រពន្ធមួយបួនហើយគ្រួសារខាងប្តីខ្ញុំបីនាក់បួននាក់និងបាត់ទាំងអស់ កូនបួនប្រាំៗនាក់និងបាត់ទាំងអស់បាត់សឹងតែម្តងអត់មានអ្នកណាតវង់ត្រកូលទៀតទេ ទៅប៉ុលពតបាត់សឹងវាចឹងណា៕

កៈ ចឹងនៅក្នុងសម័យប៉ុលពតនិងលោកយាយនៅភ្នំពេញទេ?

ខៈ អឹម សម័យប៉ុលពតនិង ជិតសិបប្រាំគេជម្លៀសអ្នកភ្នំពេញយាយទៅដល់ភ្នំស្រុកន់ថៅអើយអាជិតចប់ហើយនិង ដឹកប្រជាជនម្តងមួយឡានៗយកទៅចាក់ចោលនៅឯណាយាយមិនដឹងទេតែបាត់រហូត ហើយយាយយើងអត់ទាន់មានប្តីគេដាក់ថាយើងកម្លាំងស្រួចវាដេញជើងយើងណា យើងថាមានប្តីចឹងវាយកអ្នកមានប្តីនិងដាក់កម្លាំងស្រួច ទៅកម្លាំងស្រួចទាំងអស់ចុងក្រោយអង្គរប៉ុន្មានកំប៉ុងនិងមួយខ្ទះទៅចែកទៅរាវកឈ្លោក ហើយស្ទូងទាំងយប់ទៀតម៉ោងប្រាំបួនបានចប់ស្ទូងនិងណា ហើយយាយខ្លាចឈ្លើងនោះយាយស្រែកជួយផងគេរវល់តែរត់មកជួយបះទៅ ស្រុកនិងដឹងស្រាប់ហើយទៅហួសអើរភ្នំស្រុកហើយទៅដល់ទំពាំងថ្មហើយទៅដល់ពូងចាមហើយទៅដល់ពោយអីៗទៀតទៅនៅនិងដល់ប្រាំដែនថៃ ហើយតែយាយអត់ទៅទេ យាយសុខចិត្តមកវិញថាទៅរកបងប្អូនទៅណា ប្តិខ្ញុំអីនិងថាមករកបងប្អូនដោយដឹងថាអាណាងាប់រស់អីសឹមយើងចេញមានបានចេញទៅណានៅភ្នំពេញនិងរហូតនិងមកវិញ ហើយស្រុកនេះហែងកុំសួរអារឿងស្លាប់វិញនោះស្លាប់ឡើងស្វាត់ភូមិ ហើយ ចុះបើទៅមួយគ្រួសារៗបាត់អស់តែម្តងនិង មានបានឃើញមកវិញឯណាកំសត់ណាស់៕

កៈ ចឹង មិនមែនមួយគ្រួសារគេយកទៅតែពីរបីនាក់ទេ យកទៅទាំងអស់តែម្តង?

ខ៖ អត់ទេ យកទៅទាំងអស់ៗបើនៅភ្នំពេញវិញមកច្រកជាមួយម៉ែចឹង ដល់បែកប៉ុលពតគេដឹងថាយើងអ្នកភ្នំពេញគេយកទៅទាំងអស់ៗតែម្តង ស្ងាត់ភូមិអស់ស្ងាត់ភូមិបំផុតនិងគឹកប្រាំនិងតែម្តង អស់ហើយយកប្រុសៗទៅស្លាប់អស់ច្រើនណាស់នៅសម័យនិង៕

ក៖លោកយាយនៅសម័យកប្រាំនិងខុសគ្នាយ៉ាងម៉េចដែរលោកយាយ?

ខ៖

ខុសគ្នាត្រង់ណាម៉េចកប្រាំនិងដូចតែប៉ុលពតដែរនិង ប្រជាជននៅស្រុកនិងគ្រាន់បើដែរណា ប្រុសៗនិងណាវាមកយកទៅធ្វើកប្រាំទៀត រឹតតែអស់មនុស្សប្រុសទៀតទៅបាត់ អោយលីអីលីគ្រាប់លីអីឡើងភ្នំកុំតែចង្រៃកប្រាំនិងកុំអីអត់សូវអីទេមានមនុស្សរស់នៅច្រើនហើយ ចឹងបានថានៅសម័យប៉ុលពតនេះគ្មានអ្នកណាភ្លេច ចុះថៅឯងមើលបើកំពុងតែស្ងួងៗចឹងហ៉ំគេហៅ ហៅម្នាក់និងទៅហើយណាកាន់ដៃយើងនិងឡើងត្រជាក់ស្រៀតតែម្តង ចុះបើដឹងហើយថាតែទៅនិងដឹងតែស្លាប់ហើយយល់ហេ ប្រជុំយប់ចឹងណាហ៉ំសុខុមបងខ្ញុំលាហើយទៅអស់មួយគ្រួសារៗតែម្តង ចុះបើវាហៅអ្នកផ្ទះនិងហើយបានទៅហៅយើងនៅកន្លែងប្រជុំនិង អុំទៅនៅសម័យប៉ុលពតនិងវាងត់មានគ្រោះថ្នាក់អីទេ ប៉ុន្តែអ្នកដទៃទៀតណាចេះតែចោទគ្នាថាអញ្ចេះថាអញ្ចោះទៅណា អុំពេលទៅដល់និងមានអ្នកភូមិម្នាក់និងគេអោយយើងនៅអើតជាមួយគេចឹងទៅណាអត់អីទេសុខសប្បាយ ដល់ហើយខ្ញុំថាប៉ាយប់មិញគេហៅហ៊ាលីទៅហើយច្បាស់ជាស្លាប់ហើយគាត់អត់ជឿទេ ប៉ាឯងចេះតែនិយាយថាអត់ជឿចុះអ្នកទៅនិងមានអ្នកណាមួយដែរមកវិញអត់?? ការពិតអត់ទេគេជីកអណ្តៅរួចហើយយកយើងទៅឈូកចោលតែម្តង អ្នកខ្លះគេហៅប្តីទៅចឹងទៅណាម៉ែឃាត់កូនកុំទៅកូន ហើយទៅទៅសុខចិត្តស្លាប់ជាមួយប្តីទៅ មិនតិចទេនៅទីនេះយប់ក៏ហៅទៅវាយចោលថ្ងៃក៏ហៅទៅវាយចោល ហើយឡើងស្ងាត់ដែរភូមិខ្ញុំទៅនិងណា មកវិញសុទ្ធតែស្រីៗអត់ប្រុសៗរលីង៕

ក៖ លោកយាយភូមិដរលោកយាយទៅនិង គេហៅថាភូមិឃុំអ្វីដែរ?

ខ៖ ខេត្តសេរីសោភណ័ សង្កាត់ពន្លៃ ស្រុកនិង ស្រុកគេនិងស្រុកភូមិស្វាយសស្វាយខ្មៅអីទៅណាគេដាក់ចឹង នៅភូមិនិងហើយតែហួសតិចដល់ព្រំដែនថៃហើយខ្លះនិងយប់និងគេរត់ទៅចឹងណាប្រុសៗហាសិបនាក់រត់តាមគ្នាចឹងទៅ ដូចវាដឹងទាន់ណាវាយកទៅវាយចោលមិនតិចទេចល័តតាវិលហាស្គាល់ទេ ត្រពាំងថ្មស្អីអាងទឹកត្រពាំងថ្មនិងហើយខ្ញុំនៅភូមិនិង ជីកអានិងជីកអាអាងទឹកនឹង ជីកអាអាងទឹកនិងថៅអើយអាណិតអ្នកភ្នំពេញណាគ្នាខ្លាចឈ្លើងពេកណាយកកណ្តូរនិងកាប់ណាទៅសាច់ទាំងដុំៗសាហាវណានាងឈ្លើងប៉ុនៗនិងណាពោះវាសុទ្ធតែពណ៌លឿងតែម្តងហើយអ្នកស្រុកគេ និងក៏ខ្លាចដែរសួរគេថាកាលមុននិងស្រុកនិងស្ទូងស្រូវអីយ៉ាងម៉េចគេថាអត់ស្ទូងទេ ស្រុកគេរកស៊ីតែព្រោះតែស្រូវនោះ គេអត់ស្ទូង

ទេដល់យកយើងអ្នកថ្មីទៅគេស្ទូងទៅហើយគេអោយលោកភ្លឺស្រែណា មួយរយម៉ែត្របួនជ្រុងក្នុងមួយថ្ងៃគេដាក់ម្ភៃបួនម៉ែត្រគេអោយលើកផ្គប់គ្នាចឹងទៅណាបណ្ដោយកន្លះម៉ែត្រទទេងតែមួយម៉ែត្រទេនៅស្រុកនិងណា ង្ហកភ្នំពេញទៅលើកជាក្រឡាបួនជ្រុងទាំងអស់កាលមុនស្រូវគេមានភ្លឺដែរក៏ប៉ុន្តែស្រែធំៗបានមានភ្លឺមួយចឹងទៅណា ហើយយាយសួរគេថាក្នុងមួយគ្រួសារធ្វើស្រូវបានប៉ុន្មានក្នុងមួយឆ្នាំៗគេថា បានមួយរយថាំងគ្រាន់តែគេព្រោះទេណាដល់យើងអ្នកថ្មីទៅណាកណ្ដាប់មួយនិងទូលមិនចង់រួចផង ក្នុងមួយគូរវាមានប្រាំពីររយគ្រាប់យើងរាប់វាណាចេះតែថាមួយកណ្ដាប់វានិងយើងទូលមកវាធ្ងន់ណា ហើយអ៊ុំចេះតែមានដូរស៊ីអញ្ចឹងទៅណា អ្នកខ្លះគ្នាអត់មានអីដូរចឹងណាក្បាលជង្គុកនិងធំជាងក្បាលអស់ហើយ ចុះគ្នាម៉េចហ៊ានទៅលួចតែលួចនិងតែគេចាប់បានមិនរឹតតែធ្ងន់ទៀត ហើយមានទៅអត់អីស៊ីអ្នកស្រុកគេនិងគេមានស្រូវមនាអីកប់ទុកគ្រប់គ្នា ចឹងបានថានៅសម័យប៉ុលបតនជកុំថាធ្វើស្តតិប៉ុននិងថាប្រជាជនងាប់ប៉ុននិងមិនមែនប៉ុននិងទេ ចុះអាអ្នកដែរគ្នាបាត់បង់មួយគ្រួសារៗយើងម៉េចដឹងគ្នាបាត់ឈឹងអស់បាត់ឈឹងតែម្តង៕

កៈ នៅក្នុងសម័យនិងគេបានប្រើអោយលោកយាយ ធ្វើកម្លាំងពលកម្មធ្ងន់អ្វីខ្លះដែរ?

ខៈ ជីកប្រឡាយ ស្ទូងស្រូវ ច្រូតស្រូវ ដូចថាឥឡូវគេដាក់មកប៉ុន្មានប្រាំហិតាចឹងអោយយើងច្រូតប៉ុន្មានគ្នាហាសិបនាក់ចឹងច្រូតអោយហើយទៅតែអត់ហើយអត់បានទៀត ហើយអ្នកចង់កណ្ដាប់ដោយខ្លួនចឹងទៅ ចុងឬស្សីណាអាចុងឬស្សីគេវែងៗនិងចោះពាក់កណ្ដាលយកទៅលើហើយ យើងអ្នកនៅក្រោយចឹងគេបាចខ្ទាចមកវាធ្លាក់ផ្កាមួយក្រញុំមកណា គេបោសយកស្រូវណាផុតចុងឬស្សី ឬស្សីបីបួនដើមនិងគិតទៅនៅក្នុងស្រុកនិងភូមិតាវងភូមិខ្ញុំនៅនិងណា គ្រាន់តែច្រូតហើយបានហើយតែបីថ្ងៃអស់រលីងមិនដឹងជាបញ្ជូនតាមណាមានបានអ្នកស្រុកយើងបានស៊ីឯណា ហើយចិនគេអ្នកលូកដៃនិងណាព្រោះយើងគោពរទង់ជាតិចិន មានកណ្ដូរនិងញញួរទង់ជ័យគេនិង ថ្ងៃណាមិនយូរតែពីរយប់ប្រជុំហើយៗចឹងបានថានៅសម័យប៉ុលពតនេះកុំថាងាប់ប៉ុននិងមិនដឹងងាប់ប៉ុន្មានអាអ្នកងាប់ដាច់ពូជនេះ អាណារាយការណ៍ទាន់ចឹងបានថាវេទនាណាស់នៅសម័យប៉ុលពតហើយក្មេងៗគេថាអញ្ចេះអូយគ្នាម៉ាលកំនរមិនចេះតដៃគេតដៃម៉េច គេចង់ដៃបណ្ដើរទាំងរូងៗងាប់ច្រើនយុវជនអាណិតគ្នាហើយសុទ្ធតែអ្នកស្អាតៗចុះបើសុទ្ធតែអ្នករៀនចប់សកលរៀនចប់អី ហើយមិត្តភក្តិខ្ញុំសុទ្ធតែពេទ្យសុទ្ធតែអីនោះប៉ុន្តែអត់អីទេខ្លះបានចេញទៅក្រៅនៅសម័យនិង តាខ្ញុំគាត់មានវិទ្យុមួយស្តាប់ត្រចៀកណានាងនិ្ទគេថាបងៗជួយដូរជញ្ជៀនខ្ញុំមួយ ខ្សែដៃខ្ញុំសុទ្ធតែពេជ្រមួយជុំអញ្ចឹងទៅណាតាខ្ញុំថាកុំដូរខែមួយនិងចប់ហើយស្រាប់តែខែមួយនិងគេវាយចូលតាមស្ពានច្បារអំពៅ យើងដឹងទាំងអស់ហើយណាមីនិងសំណាងហើយបានតាខ្ញុំអត់អោយដូរសុខចិត្តអោយអង្គរវាបួនប្រាំកំប៉ុង

យកទៅស៊ីក្រែងស្រុកចប់ទៅហែងបានទៅស្រុកក្រៅវិញ ឥឡូវនិងវាបានចេញក្រៅទៅបាត់ទៅនុងបើសិនជាមកភ្នំពេញវារកព្រោះខ្ញុំប្រាប់វាថាខ្ញុំនៅកោះដាច់សួរតែឈ្មោះខ្ញុំទៅអ្នកណាក៏គេស្គាល់ដែរ ហើយមីមួយទៀតរៀនពេទ្យចប់ដែរណា វាថាគេយកគ្រួសារវាយទៅទាំងអស់នៅតែវាមួយទេណាគេទៅតាមទ៨ហៅយកគ្នាទៅតាមទៀតនាងឯងមើល ព្រោះខ្ញុំយំអញ្ចឹងទៅណាចុះមនុស្សនៅជាមួយគ្នារហូតហែងគិតមើលយកគ្នាទៅដែរ មិនអាណិតអីសោះហើយមួយទៀតបងវានិងធ្វើពេទ្យនៅស្រុកបារាំងដល់ពេលមកចឹងណា គាត់រកគ្រូទាយថាខ្ញុំថ្ងៃពីរថ្ងៃអីចឹងខ្ញុំត្រូវចេញទៅស្រុកគេវិញចឹងទៅណាហើយគ្រូទាយថាអត់បានទៅទេចៅឯងត្រូវស្លាប់នៅស្រុកខ្មែរនិងតែម្តង មានណាទៅយន្តហោះវាអត់ឡើងរហូតគ្នាទៅប៉ុលពតទៅអាមួយទៀតវាវាយការណ៍យកទៅមួយគ្រួសារសម្លាប់ទាំងអស់សុទ្ធតែមិត្តភក្តិខ្ញុំទាំងអស់ គ្មានអ្នកណារស់មួយទេងាប់អស់ហើយខ្ញុំគេអោយធ្វើប្រធានក្រុមនិងក្តាប់អ្នកដប់នាក់និងដាក់គ្នាឈប់ ម្នាក់ឈប់ពីរថ្ងៃចឹងទៅដល់ថ្ងៃក្រោយម្នាក់និងចូលអោយម្នាក់ទៀតឈប់បន្តទៀត ហឹមពិបាកណាស់មិត្តនារីនេះឈប់ម្តងពីរនាក់រហូត មារហែងគេអោយហៅមារៗស្រុកនិង មារហើយបើយើងមិនឈប់មានកម្លាំងណាទៅតតាំងបានត្រូវតែឈប់ចឹងហើយ ដប់នាក់ក៏មានម្នាក់ឈឺដែរយើងពន្យល់ចឹងទៅណាគេក៏អត់មាត់ដែរខ្ញុំទៅរហូតស្អីសង្កាត់ពយចាម ណាំណារ រអាងថ្មភ្នំស្អីគេហៅរអាងអីជញ្ជៀនគេប៉ុនៗនិងនៅភ្នំនិងណាគេតម្កល់ទុកនៅនិងម៉ង ចាស់ពីដើមមាឌធំៗណាស់ជញ្ជៀនប៉ុនៗនិង ណាំតារណាំស្អីថាដើរមិនដឹងជាស្អីទេ លេងស្គាល់អស់យូរទៅតែខ្ញុំចាំថាថ្ងៃមួយខ្ញុំលើកប្រឡាយនិងណាជិតព្រះវិហារណ៎ខ្ញុំសួរថាស្អីគេ

គេប្រាប់ថាព្រះវិហារអ្នកស្រុកគេប្រាប់ចឹងណា ចុះយើងណាទៅហ៊ានដើរទៅយើងងូតទឹកស្ទឹងនិងដើរគ្រប់ទាំងអស់ពួកខ្ញុំនិង ហើយដើរទៅកន្លែងថ្មគេហៅថាស្ពានស្អីគេនិងមើលទៅក្រោមទៅណាចៅអើយសុទ្ធតែអ្នកកំពុងតែកាន់ថ្ម ចងសុទ្ធតែច្រវ៉ាក់រាប់រយនាក់សុទ្ធតែប្រុសៗងាប់វាគ្មានទៅលែងយើងទេ៕

កះនៅក្នុងសម័យប៉ុលពតនិង តើហេតុការណ៍អ្វីដែរលោកយាយចាំមិនភ្លេចដែរ?

ខះ ចាំមិនភ្លេចចាំត្រង់ថាយើងបែកបាក់បងប្អូន វាសម្រាប់ចោលគ្មានរើសមុខខ្ញុំសួរវាថាអានិងអ្នកមេសម្លាប់ណាថា ហេតុអីបានចេះតែយកគ្នាទៅសម្លាប់ចឹង??មិនមែនទេបងគ្មានអ្នកណាគេចង់សម្លាប់ទេ គេអ្នកដាក់ទិសមកដូចថាបើចិនគេយកទៅទិសភូមិផ្សេងចឹងទៅណាអូនអើយស្លៀកពាក់សុទ្ធតែរ៉ូបក្រហម រ៉ូបអីចឹងស្អាតៗណាស់ អត់ដឹងថាគេយកទៅសម្លាប់ទេយកទៅចឹងសើចដាក់ឯង បងអើយខ្ញុំលាហើយកូនមីងអើយខ្ញុំលាហើយ គ្នាអត់ដឹងណាគ្នាសប្បាយក្នុងចិត្តណាបានគេយកទៅភូមិផ្សេង តែអត់ទេយកទៅសម្លាប់ហើយខ្ញុំសួរថាហេតុអីគ្នាធ្វើការសកម្មប៉ុននិងហេតុអីយកគ្នាទៅទៀត ថាបើមិនយកវាមានតែយកខ្មែរអាអ្ន

កសម្លាប់វានិយាយចឹងម្លោះហើយត្រូវយកចិន
ហើយនិងកម្ពុជាក្រោមយកតែពួកនិងទេ អោយតែនិយាយរជឹនៗវាយកទៅទាំងអស់៕

ក៖ ចុះដូចអ្នកសៀមវាបពួកគាត់និយាយអត់សូវច្បាស់ និយាយរជឹនៗចឹងតើគេយកពួកគាត់ទៅសម្លាប់ដែរទេ?

ខ៖ អានិងអ៊ុំអត់ដឹងដែរ មានពួកសេរីសោភណ័ណាទៅដល់និងដែរវានិយាយពិរោះៗណាស់ពួកនិងយើងដឹងណាពយកសេរីសោភណ័ពួកខ្ញុំនៅលេងជាមួយវាទេ មិនដឹងរឿងអីតេដូចវាចេះតែនឹកឃើញចង់តសម្លាប់ចឹងពយកនុង ក្នុងមួយយប់ដូចថាមានហាសិបស៊ីដាច់ហាសិបនាក់ សាហាវណាស់តែវាប្រាប់យើងណា បើមិនយកវាយកស្បែកខ្មៅមិនចឹងនេ បានវាចេះតែយកពួកនិងនោះ វាយកច្រើននតែចិនហើយនិងពួកកម្ពុជាក្រោម ងាប់អស់ៗដាច់ពូជគាត់និងតែម្តង ដឹងម៉េចអត់អ៊ុំទៅកម្ពុជាក្រោមនិងណាអ៊ុំសួរគេ នៅសម័យប៉ុពតនិងពួកវាគេជម្លៀសចេញដែរនិងកម្ពុជាក្រោមណា ហើយខ្ញុំថាចុះហេតុអីចប់ទៅម៉េចមិនវាយយកពួកនិងមកវិញ ថាអត់ដឹងដែរស្រាប់តែចេញមកវិញយួនមកយកតែម្តងភូមិក្រាំងក្រូច កាលប៉ុលពតគាត់ចេញដូចតែយើងដែរនិង មិនត្រឹកយកតែយើងទេណាពួកកម្ពុជាក្រោមដែរជិតព្រំដែរននិងក៏ជម្លៀសគ្នាទៅដែរណា ទៅខ្ញុំទើបតែដឹងរឿងតើពេលខ្ញុំទៅលេងនិង៕

ក៖ លោកយាយ តើលោកយាយមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះតន់ យាយតន់៕

ក៖ ទាំងត្រកូលរបស់លោកយាយ មានឈ្មោះអ្វីដែរ?

ខ៖ ធូ តន់៕

ក៖ កាលពីនៅក្មេង លោកយាយមានឈ្មោះហៅក្រៅពីធូតន់និងដែរទេ?

ខ៖ អត់ទេ ឈ្មោះខ្ញុំតែមួយនឹង៕

ក៖ សព្វថ្ងៃលោកយាយ មានអាយុប៉ុន្មានដែរហើយ?

ខ៖ មើលខ្ញុំអាយុជិតសិបបីហើយឆ្នាំនិង៕

ក៖ លោកយាយ តើលោកយាយនៅចាំឆ្នាំខ្មែររបស់លោកយាយ តើលោកយាយកើតនៅក្នុងឆ្នាំមួយណាដែរ?

ខ៖ ឆ្នាំមួយប្រាំបួនរយសែសិបប្រាំ៕

ក៖ ចឹងហ៎

ខ៖ ចាស!

ក៖ ចុះឆ្នាំខ្មែរយើងក្នុងឆ្នាំទាំងដប់ពីរ តើលោកយាយកើតក្នុងចំណោមឆ្នាំមួយណាដែរលោកយាយ?

ខ៖ ខ្ញុំឆ្នាំចរ៕

ក៖ តើទីកន្លែងកំណើតរបស់លោកយាយ នៅភូមិឃុំអ្វីដែរ?

ខ៖ ពីដើមគេហៅខេត្តកណ្ដាល សង្កាត់កោះដាច់ឥឡូវយើងចូលមកខណ្ឌជ្រោយចង្វារិញហើយ រាជធានីភ្នំពេញចាស៕

ក៖ នៅក្នុងក្រុមគ្រួសាររបស់លោកយាយ មានបងប្អូនចំនួនប៉ុន្មាននាក់ដែរ?

ខ៖ មើលខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំមួយនាក់ ស្លាប់អស់បីនៅបី ស្លាប់និងស្លាប់ទាំងកូនទាំងប្រពន្ធអីអស់តែម្ដងចុះបងខ្ញុំគាត់ធ្វើទាហ៊ាននោះវាម៉េចិងទុក តែសម័យប៉ុលពតគេអោយគាត់និងជួយដឹកអង្ករដឹកស្រូវដែរណា ប៉ុន្តែមិនដឹងជាយ៉ាងម៉េចទេប្រពន្ធជាប់គេអ្នកស្គាល់និងគេថាគាត់ស្លាប់ហើយ ព្រោះគេយកគាត់ចឹងណា៕

ក៖ លោកយាយ ជាកូនទីប៉ុន្មានក្នុងគ្រួសារដែរ?

ខ៖ ខ្ញុំកូនទីប្រាំនៅសល់ប្អូនពៅមួយទៀត ប្អូនពៅនិងនៅសម័យមុនជិតសិបប្រាំនិងណាវាទីធ្វើជាមួយនិងស្មិកាលនិងចាញ់បោកថាតាសីហានុអំពាវនាវធ្វើត្រីមាគីអីគេនោះគ្នាទៅធ្វើបាត់ខ្លួនទៅ ប៉ុន្តែនៅឆ្នាំជិតសិបប្រាំនិងវានោរស់ទេ តែក្រោយមកគេថាវានិងស្លាប់ត្រូវគ្រាប់ត្រូវអីកំពុតជើង ដល់ពេលពួកពោពុកខ្ញុំទៅនិងក្រុមគ្រងពួកពោដល់ពួកនារតីទៅថាពួកនារតីនិងក្បត់ យកពួកពព៌និងទៅសម្លាប់បព្ចុម្ដងទៀតនៅសម័យប៉ុលពតនិង ចឹងបានថាវាសម្លាប់បន្តគ្នាចឹង៕

ក៖ ចឹងអត់មានមួយថ្ងៃណា ដែរអត់សម្លាប់ទេ?

ខ៖ អត់មានទេ ទិសត្រូវតែគេសម្លាប់ចឹង តែគ្រាន់ថាជួនកាលពពួកនិងនិយាយថា យប់ព្រលប់ៗចឹងមកពីចំការគេអោយធ្វើចំការពូស្នូរខ្ញុំមានកំហុសអីស្រែកចឹងទៅណា ស្រែកខ្ញុំមានកំហុសអីបានជាយកខ្ញុំមកសម្លាប់ ស្រែកល្វើយៗចឹង ប៉ុន្តែឃោឃៅណាស់ឃោឃៅត្រង់ថាមុននិងវាសម្លាប់ណាវារំលោភអស់ហើយ រំលោភឡើងទន់ខ្លួនទើបវាយកទៅអាក ហើយអាកនិងមិនមែនអាតែម្នាក់ទេណា អាបន្តិចម្ដងៗចឹង ហេតុការណ៍និងបានខ្ញុំដឹងណា ថ្ងៃឡើងខ្ញុំទៅស្ទូងជាមួយមិត្តនារីផ្ដាច់ខ្លួនគេចុះនារីត្រូវគេមកមើលប្អូនប្រាំនាក់ គេចាំសើបការពីយើងចឹងណាវានិយាយថា ហឹមអាណិតអាគៀងណាអាកម្នាក់បន្តិចៗទម្រាំតែងាប់ ចឹងបាន

ខ្ញុំដឹងនិងថាគេធ្វើចឹងតើ មិនមែនងាប់ដោយស្រួលណាចុះវារូបស្អាតនោះ ពួកប្រុសៗវានិយាយថាហឹមសូម្បីតែស្រមោចក៏វៀរទៅជ្រុះដែរសាច់វាស្អាតនោះ ចុះពួកនិងដឹងស្រាប់ហើយចេញពីភ្នំពេញនិងទៅឈ្វេងៗ ចុះវាមិនដែរឃើញហើយវាថាចុះអ្នកភ្នំពេញនិងអីក៏ស្អាតៗម្លេះ វាចេញបោកគេដែរពួកនិងនោះ គេថាបើវាយភ្នំពេញបានគេនិងទិញម៉ូតូអាសង់អោយមួយម្នាក់ ហើយអ្នកស្រុកនិងអត់ដឹងអីទាំងអស់គេមកប្រាប់ណា កូនអ្នកឯងពលីហើយគេសើចហាហាហាហា កូនខ្ញុំគេបានពលីហើយណាគេផ្ញើរខោអាវផ្ញើរអតសញ្ញាណប័ណផ្ញើរកាតនិងមក អត់ដឹងថាពលីនិងស្លាប់ណាទល់តែពួកនិងទៅផុតបានប្រាប់ថាយាយពលីនិងបានន័យថាស្លាប់ បានទ្រហោយំពួកវានិងក៏ចឹញបោកគេដែរ គ្នាអ្នកស្រុកនិងមិនមែនធម្មតាទេ ហើយស្រុកគេគេធ្លាប់រស់អោយសុខសាន្តគេធ្លាប់ធ្វើស្រូវគេធ្លាប់អី តែចុងក្រោយអានមេកងមេអីនិងក៏យកគ្នាទៅដែរ ដូចសម្លាប់បន្តគ្នាតែម្តង៕

កៈ បងប្អូនរបស់លោកយាយ ពួកគាត់មានឈ្មោះអ្វីខ្លះដែរលោកយាយ?

ខៈ ចាំមើលបងបង្អស់ឈ្មោះធូ ផាន់នៅរាស់រាល់ថ្ងៃនិង បានទៅធូទី ធូតាង ធូជន់ អ្នកនិយាយនិងធូ តន់ ហើយធូចាន់ស្លាប់ហើយ ស្លាប់អស់បីនៅបី ៕

កៈ សព្វថ្ងៃបងប្អូនរបស់លោកយាយ ទាំងបីនាក់និងពួកគាត់ធ្វើអ្វីដែរ?

ខៈ អត់ទេ បងខ្ញុំមួយនៅភ្នំពេញ ហើយខ្ញុំនៅកោះនិងរាល់ថ្ងៃនិង ខ្ញុំទៀបតែធ្វើផ្ទះមកនៅនិងទេ ហើយបងខ្ញុំមួយទៀតគាត់នៅភ្នំឧរ៉ាល់ កំពង់ស្ពឺហ៎ គាត់នៅរស់ដែរ៕

កៈ ពីក្មេងចឹង តើលោកយាយមានអានុស្សាវរីយ៍អ្វីខ្លះជាមួយនិងបងប្អូនរបស់លោកយាយដែរ?

ខៈ ហឹម រស់ដោយសុខសាន្តណាស់កូន បើយាយនៅតែត្បាញនៅភ្នំពេញនៅកោះនិង យាយងត់បានធ្វើអីទេយាយនៅតែត្បាញនៅជាមួយម្តាយរបស់យាយទេ ធ្វើតែត្បាញនិងរស់ដោយស្រួលហើយធ្វើចំការនៅខាងត្រើយនិងទៅ ខែពោតយើងធ្វើពោតនៅនិងទៅដល់ខែពោតយើងកាច់ដឹកកាណូតយមកផ្ទះមកហើយនៅមុខផ្ទះនិងយើងទុក ហាលពោតមុខផ្ទះនិងដល់ភ្លៀងមកនាំគ្នាយកពោតនិងមកទុកទៅបើអាណាត្រូវទឹកភ្លៀងជួយទាំងអស់គ្នាចឹងទៅជួយគ្នាទៅវិញទៅមក៕

កៈឪពុកម្តាយរបស់លោកយាយ ពួកគាត់មានឈ្មោះអ្វីដែរលោកយាយ?

ខៈ ឈ្មោះធូ ជួប ម្តាយរបស់ខ្ញុំឈ្មោះប៉ាច់ ទឹប ចាស ស្រុកកំណើតរបស់គាត់នៅនិងទេណា គាត់ស្លាប់អស់ប៉ុន្មានតំណហើយ៕

កៈ ឪពុករបស់លោកយាយតើលោកយាយដឹងដែរទេថាអាយុរបស់គាត់ប៉ុន្មានដែរហើយ?

ខ៖ ឪពុកខ្ញុំបើគាត់នៅ គាត់ក៏មានអាយុច្រើនដែរហើយ ប្រោះគាត់ស្លាប់តាំងពីខ្ញុំអាយុប្រាំពីរឆ្នាំ ចាសម៉ែខ្ញុំមើលថែទាំគាត់រហូត តែកូនចៅគាត់សុទ្ធតែអោយរៀនរហូត អាបងនោះប្រលងឌីប្លូមហើយបានឈប់រៀន អាមួយទៀតបានប្រលងបាក់ឌុកទៅរៀននៅព្រែកអញ្ចេញទៅ សុទ្ធតែអោយរៀនទាំងអស់ទោះបីក្រម៉េចក៏ដោយអ្នកស្រុកនិងយាយឃើញណាទោះក្រម៉េចក៏គេអោយកូនគេរៀនដែរ មិនសូវមានអ្នកអត់ចេះទេសូម្បីតែយាយនិងរៀនបានត្រឹមថ្នាក់ទី៦ទី៧ដែរបានយាយឈប់និង ចុះយើងអត់ឈប់ម៉េចបានបើម៉ែយើងមេម៉ាយប្អូនយើងរៀនបងយើងរៀន យើងស្រីត្រូវដកឃ្លាឈប់ទៅយាយនៅត្បាញទៅអោយប្អូនរៀនទៅរៀនថ្ងៃសៅរ៍ថ្ងៃអាទិត្យមកផ្ទះចឹង អោយលុយទៅរៀនទៅ៕

ក៖ កាលពីឪពុករបស់លោកយាយ ស្លាប់និងគាត់មានអាយុប៉ុន្មានដែរ?

ខ៖ អ៎ គាត់ស្លាប់មុនប៉ុលពតទៀត បើម្ដាយខ្ញុំនៅទេគាត់ទើបតែស្លាប់ចប់ប៉ុលពតទេ ប្រោះអីខ្ញុំនៅឯភ្នំស្រុកនោះខ្ញុំមានបានជយនគ្នាឯណា គាត់ស្លាប់ហើយប៉ុន្មានឆ្នាំបានចប់ កើតទុក្ខនិងបាត់បង់កូនទៅណា៕

ក៖ ឪបុករបស់លោកយយា កាលគាត់នៅមានជីវិត តើគាត់ប្រកបរបរអ្វីចិញ្ចឹមក្រុមគ្រួសារដែរ?

ខ៖ គាត់ធ្វើចំការហើយគាត់ធ្វើពេទ្យដើរចាក់ថ្នាំ គាត់អត់ចេះអង់គ្លេសទេគាត់ចេះតែបារាំងទេជំនាន់នុងចឹងហើយបានឆ្លងមកពូជពង្សសុទ្ធតែបានរៀនទាំងអស់ ផ្ទះនេះសូម្បីក្រកូនគាត់រៀនទល់តែចប់សុទ្ធតែធ្វើការធ្វើអីនៅភ្នំពេញ៕

ក៖ ឪពុករបស់លោកយាយ តើគាត់ជាមនុស្សបែបណាដែរ ស្លូតឬក៏កាចដែរលោកយាយ?

ខ៖ ស្លូតណាស់ គាត់ចេះប្រៀនប្រដៅកូនអ្វីដែរគួរធ្វើអ្វីដែរមិនគួរធ្វើ យើងជំនាន់និងគ្មានទៅភ័យថា មានថ្នាំញ្ញៀនមានអីដូចឥឡូវនិងទេ មិនស្គាល់ថ្នាំញៀនទេ កូនមួយណាដឹងតែគោរពឪពុកម្ដាយចាស់ទុំសុទ្ធតែស្លូតៗទាំងអស់បងប្អូនយើង គ្មានចេះប្រើពាក្យឈ្លើយណាដូចថានិយាយចេញមកសមរម្យទាំងអស់ដល់មកនិយាយសម័យឥឡូវនេះ កូនយាយក៏រៀនដែរសុទ្ធតែចប់ទាំងអស់៕

ក៖ ចាស ម្ដាយរបស់លោកយាយ តើគាត់ធ្វើអ្វីដើម្បីចិញ្ចឹមក្រុមគ្រួសារដែរ នៅពេលដែរគាត់អត់ពីស្វាមីរបស់គាត់ទៅ?

ខ៖ មានតែធ្វើស្រែ ធ្វើចំការធ្វើត្បាញនិងតែប៉ុននិង អត់មានធ្វើអីទេប៉ុន្តែអាចចិញ្ចឹមគ្រួសាររស់ស្រួល៕

កៈ កាលពីលោកយាយ នៅពីក្មេងតើឪពុកម្តាយរបស់លោកយាយ ពួកគាត់មានបានធ្លាប់ប្រាប់ពីសាច់រឿងជីវប្រវត្តិរបស់គាត់អោយលោកយាយស្តាប់ដែរទេ?

ខៈ គាត់អត់មានសាច់រឿងអីកំសត់នោះទេ គាត់បានប្តីប្រពន្ធគាត់មកសុទ្ធតែស្ដីដណ្ដឹង ចឹងទៅណា៕

កៈ លោកយាយ តើលោកយាយនៅចងចាំឈ្មោះជីដូនជីតាខាងម្តាយរបស់លោកយាយដែរទេ?

ខៈ គាត់នៅកោះនិងដែរតើ មើលគាត់ឈ្មោះតាប៉ិច យាយអីទេនេះភ្លេចបាត់ហើយ ឈ្មោះយាយដើមឈ្មោះគាត់និងនៅនិងកោះនិងដែរទេ៕

កៈ ចុះជីដូនជីតាខាងឪពុកវិញ តើលោកយាយនៅចាំឈ្មោះពួកគាត់ដែរទេ?

ខៈ ជីដូនជីតាខាងឪពុកគាត់នៅ ព្រៃសរណ៌ ចាសបងប្អូនគាត់សុទ្ធតែប្រុសទាំងអស់ បងប្អូនគាត់តាមស្តាប់ទៅបងគាត់មួយក៏ធ្វើពេទ្យដែរតែស្លាប់អស់ហើយ គ្មានអ្នកណានៅទេស្លាប់នៅសម័យប៉ុលពតនិងតែម្តង តែអត់មានអ្នកណាវៃយចោលទេស្លាប់ដោយដារជំងឺគាត់ដូចថារាកទៅស្លាប់ទៅអត់មានអ្នកណាវៃគាត់ចោលទេ តែនៅសល់កូនកូននិងក៏ដាច់ពូជអស់ហើយធ្លាប់សួរទៅកាលនៅបាត់ដំបងថានៅដែរនៅកូនពិរបីដែរ?

កៈ ជីដូនជីតាខាងឪពុករបស់លោកយាយ គាត់មានឈ្មោះអ្វីដែរលោកយាយ?

ខៈ ជីដូនជីតាខាងឪពុកខ្ញុំគាត់ឈ្មោះតាធូ តែមិនដឹថាយាយអីទេភ្លេចបាត់ហើយ ចាសខ្មែរយៈគាត់ធូទាំងអស់៕

កៈ ចាស
ចឹង ជីដូនជីតារបស់លោកយាយរស់នៅខេត្តកណ្តាលនេះតែសព្វថ្ងៃគេហៅថា រាជធានីភ្នំពេញ និងអស់រយៈពេលយូរដែរហើយលោកយាយ?

ខៈ ចាស គាត់រស់នៅនិងដែរ តាំងពីសង្គមមកខ្ញុំកើតមកម៉ែឪខ្ញុំរស់នៅនិងតែម្តង៕

កៈ ចាស ចឹងតើលោកយាយមានបងប្អូនឬក៏សាច់ញាតិណាដែរគាំត់រស់នៅក្រៅប្រទេសដែរទេ?

ខៈ អត់មានខ្ញុំហ៎ បើសិនណាជាគេទៅនៅក្រៅប្រទេស យើងបាត់ខ្លួនទៅយើងដឹងថាគេទៅណាសយើងអត់ដឹងទេណា បើសិនណាជាគេនៅស្រុកក្រៅក៏គេមកស្រាវជ្រាវរកដែរមិនចឹង នេះដូចអស់សង្ឃឹមហ្មងអត់មានណានៅទេ ព្រោះយើងសុទ្ធតែអ្នកធ្វើការយើងមិនអាចនៅទេ៕

កៈ ទាក់ទងទៅនឹងចំណងអាពាហ៍ពិពាហ៍របស់លោកយាយវិញ តើស្វាមីរបស់លោកយាយគាត់មានឈ្មោះអ្វីដែរ?

ខៈ គាត់ឈ្មោះចា ផាន់សុង ៕

កៈ គាត់មានអាយុប៉ុន្មានដែរហើយលោកយាយ?

ខៈ តាខ្ញុំគាត់ទើបតែស្លាប់តើ ស្លាប់៧៦គាត់ស្លាប់ជាងពីរឆ្នាំហើយគាត់ឈឺតើខ្ញុំទៅដេកនៅស្រុកយួន គាត់ធ្វើនៅមន្ទីសារព័តមានខេត្តកោះកុងគាត់ទើបតែចូលនិវត្តន៏ទេ ពីមុនគាត់ដើរជាមួយខៀវកញ្ញារិទ្ធអីនិង ដល់ពេលគាត់ស្លាប់ទូរស្ទព័ទៅក៏គេមិនលើកមិនអីចឹងទៅណាគ្មានបានអីទេ គាត់ស្លាប់ទៅនិងយើងបានលុយមួយពាន់ជាងដែរចូលនិវត្តន៏និងណា៕

កៈ គាត់ធ្វើធំដែរនិងណាលោកយាយ គាត់ធ្វើជាមន្ទីរសារព័តមានហើយ៕

ខៈ និងហើយ គាត់ធ្វើធំដែរតើ ចាសធ្វើធំនិងហើយបានគេថាស្តាយកុំយកទៅស្រុកយួនទៅមានអី ៕

កៈ លោកយាយ តើលោកយាយនៅចាំឆ្នាំដែរលោកយាយរៀបអាពាហ៍ពិពាហ៍និងដែរទេថានៅក្នុងឆ្នាំណាដែរ?

ខៈ ឆ្នាំមួយពាន់ប្រាំបូនរយជិតសិបប្រាំបូនហើយ៕

កៈ ចឹងបានន័យថា បែកពីជំនាន់ប៉ុលបតហើយបានលោកយាយរៀបការ?

ខៈ និងហើយ ៕

កៈ មូលហេតុអីបានជាលោកយាយ ស្គាល់គ្នាជាមួយនិងលោកតាដែរនៅពេលណា?

ខៈ ស្គាល់គ្នានៅពេលទៅប៉ុលពតជាមួយគ្នានិង ដល់ពេលមកវិញរៀនចំទៅ៕

កៈ នៅពេលដែរលោកយាយ រៀបអាពាហ៍ពិពាហ៍និងមានថ្លៃជំនួនអីដែរទេលោកយាយ?

ខៈ អត់ ជំនាន់និងអត់មានផងយើងក៏អត់បងប្អូនគេក៏អត់ បងប្អុនរៀបរយធម្មតាចឹងទៅ ហើយបានកូនបូននាក់៕

កៈ ពួកគាត់សព្វថ្ងៃនៅសិក្សាឬក៏ធ្វើការអស់ហើយដែរលោកយាយ?

ខៈ ធ្វើការអស់ហើយឥឡូវហ៎ តែនៅកំលោះមួយគេមិនទាន់យកប្រពន្ធហិហិហិ កំលោះនិងអាយុសាមជាងហើយ៕

ក៖ ចាសចឹង លោកយាយភាសាខ្មែរកាលពីលោកយាយនៅក្មេងលោកយាយចេះអានសរសេរបានល្អដែរទេ?

ខ៖ មានអីខ្ញុំខ្មែរនៅចាំទាំងអស់និង តែភ្លេចបារាំងជំនាន់និងរៀនភាសាបារាំងទេ ភ្លេចអស់ហើយបារាំងនោះបើខ្មែរមានតែស្អី យើងអាចនោចាំបានទាំងអស់សរសេរអីអត់មានភ្លេចទេ អាននិងមានប្រាំពីរដូចជាពាក្យរបាយការណ៍ ហេតុការណ៍អីអាណាដែរត្រូវមានរអាណាដែរត្រូវអត់រចឹងយើងចាំអានិងហើយដូចថាក្រៅពីនិងអត់មានទេ៕

ក៖ ភាសាបារាំងដែរលោកយាយរៀននិងកាលនិង លោកយាយរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ចាំមើលណាបារាំងណាតែចូលទៅពីរបីថ្នាក់រៀនហើយ ជំនាន់និងហ៎យាយមិនចាំដែរហារៀនភាសាបារាំងយើងមើលដាច់ដែរប៉ុន្តែឥឡូវយើងភ្លេចអស់ហើយ ចាសចុះបើវាខុសគ្នាពីដើមយើងពេអុយ ពុយចឹងទៅណាតែដល់ពេលឥឡូវវាដូចខុសគ្នាអីតិចៗម៉េច ដូចចាំមិនបានបើតាខ្ញុំគាត់ចេះភាសាបារាំងស្ទាត់គាត់អាចមើលអង់គ្លេសបានទៀត គាត់ពូកែណាំស់ថាទៅគាត់ធ្វើការណាស់៕

ក៖ ចាសចឹង លោកតាគាត់ចេះភាសាបារាំងផង អង់គ្លេសផង?

ខ៖ អត់ទេ គាត់គ្រាន់ថាគាត់បង្ហាត់ថៅទៅគាត់អាចរៀនបាន ក្មេងឥឡូវឆ្លាតៗណាស់៕

ក៖ ចាស តាំងពីលោកយាយរៀនបានត្រឹមថ្នាក់ទីប្រាំពីរទីប្រាំបីអីចឹងណាលោកយាយ!

ខ៖ ជំនាន់និងណា យើងរៀនថ្នាក់ទីមួយទីពីរអីគេរាប់ចឹងទៅណា ហើយទៅយើងឌើរនិងបានន័យថាយើងថ្នាក់ទីប្រាំមួយហើយចាស បានប៉ុននិងទេឈប់រៀនទៅ៕

ក៖ កាលពីលោកយាយនៅរៀននិង លោកយាយរៀននោសាលាណាដែរលោកយាយ?

ខ៖ សាលាកំពង់ពេជ្រយើងនិងនៅវត្តយើងនិង ៕

ក៖ កាលពីលោកយាយទៅរៀននិង តើលោកយាយធ្លាប់មានលុយចាយដែរទេលោកយាយ?

ខ៖ អត់ទេៗៗ អត់មានលុយក៏បានដែរជំនាន់និង៕

ក៖ មកដល់សព្វថ្ងៃនេះ តើលោកយាយមានមិត្តភក្តិដែរធ្លាប់រៀននៅសាលាជាមួយគ្នានិងដែរទេលោកយាយ?

ខ៖ ខ្វះអីមួយគំនរ នៅរស់មួយគំនរ៕

កៈ ផ្ទះនៅជិតៗគ្នានិង?

ខៈ ផ្ទះនៅជិតគ្នានិង ខ្លះរៀនបានពីរបីថ្នាក់ក៏ឈប់ទៅ តែម៉ែខ្ញុំអោយទៅរៀនដាក់សៀវភៅទៅមានលុយក៏ទៅអត់លុយក៏ទៅ គ្មានរៀនគួរគ្មានអីទេពីដើមហ៎ មិនដូចឥឡូវឯណារៀនផងរៀនគួរផង៕

កៈ ចុះខ្ញុំឭថា កាលពីមុននិងរៀនពីរវេនផងលោកយាយ ទាំងព្រឹកទាំងថ្ងៃ?

ខៈ ព្រឹកក៏រៀនល្ងាចក៏រៀនដែរ ហើយមិនមែនដូចឥឡូវថាសិស្សពូកែពូកែគណិត ពូកែគីមីចឹងហាគឺអត់ទេពីមុនណាមនុស្សដែររៀនពូកែគឺពូកែទាំងអស់ ទាំងគណិតវិទ្យាគិមី ហើយនិងស្អិតេទេរូបជីវអិនិងពូកែទាំងធអស់តែម្តង៕

កៈ កាលពីលោកយាយនៅពីក្មេង តើលោកយាយធ្លាប់បានដើរស៊ីឈ្នួលគេដើម្បីយកប្រាក់កម្រៃមកអោយក្រុមគ្រួសារដែរទេ?

ខៈ យី ទៅស៊ីឈ្នួលដែរតើទៅកាច់ពោតនិង ឧបមារថាមួយហិតាប៉ុន្នានយើងគុណជាការទៅណា មួយហិតានិងសាមសិបរៀលនិងយើងធ្វើតែបីនាក់និងទៅហើយមួយហិតានិងហាដល់ពេលដល់ខែសកាច់ពោតយើងទៅកាច់ហើយចោលត្បាញសិនហើយ យកលុយមកហើយយកលុយនិងមកទៀតក៏អត់ដឹងចាយខ្លួនឯងដែរ អោយម៉ែអស់ៗ៕

កៈ ចាស នៅពេលនិងដូចអត់មានចាយលុយអីផងនិងលោកយាយ?

ខៈ ចាស អត់មានទេ បើឃើញគេស្លៀកហូល អូម៉ែកូនចង់ស្លៀកហូលមួយ គាត់យកសំពត់យកអីទៅលក់គាត់ទិញយកមកអោយមួយមក អត់ចេះដឹងថាយកទៅចាយនេះចាយនោះអត់ដឹងទេ យើងដឹងតែថាបានលុយមកអោយម៉ែហើយអត់មានចង់បានអីទេ ចង់បានមាសពាក់ចឹងគាត់ទៅទិញយកមកអោយមក និយាយរួមអត់មានចង់បានអីចង់បានតែអោយម៉ែតែម្តង វាចឹងណាហើយត្បាញមកយកទៅលក់ចឹងម៉ែយកលក់ៗទៅមានតែចឹង ជំនាន់និងគឺដូចគ្នាចឹងអត់មានទេ៕

កៈ ជីវភាពរបស់លោកយាយ កាលពីមុនមកដល់ពេលឥឡូវនេះមានការផ្លាស់ប្តូរអ្វីខ្លះដែរ?

ខៈ វាច្រើនតែផ្លាស់ប្តូរហើយ ដូចថាសម័យនេះយើងអាណិតកូន កូនទៅធ្វើការទាំងប្តីទាំងប្រពន្ធចឹងបើជំនាន់មុន ហូបឆ្អែតមានលុយមានលុយសល់ទិញស្រូវដាក់ផ្ទះចឹង វាអត់មានពិបាកអីគេទេ៕

កៈ កាលពីលោកយាយនៅក្មេង ចំណង់ចំណូលចិត្តរបស់លោកយាយចូលចិត្តបរិភោគអាហារអ្វីដែរ?

ខ៖ អត់មានទេ មានតែស្លរទំពាំង ស្ងោរ សម្លក់អីតែប៉ុននិងតែរបស់និងវាអត់មានជាត់គីមីអីទេ ចង់ស្ងោរស៊ុបជំឡូងស្ងោរទៅ បើជំឡូងយើងនិងទុកចោលទៅវាដុះទៅដល់ខែទៅយើងកាត់តែក្បាលពុះវាទៅយើងបណ្ដុះវាទៅ ថាស្អីក៏អត់អត់ដែរជំនាន់នុងនោះ មានគ្រប់ផ្ទះចឹងតែម្ដងហើយមិនចេះលួចទៀត ចាស់ៗដឹងតែចែកគ្នាហូបអត់មានទៅរិវរល់អូយើងបានមកយើងលក់អីងត់ទេ បានមកចែកអ្នកជិតខាងស្លរទៅ ហើយនឹកឃើញមុនជិតសិបប្រាំក៏ដោយដើរទៅភ្នំពេញមកវិញទិញតាំងពីសាច់គោសាច់ជម្រៀសគេ ទិញអានិងមកស្ងោរស៊ុបមួយឆ្នាំងប៉ុននិងទៅ ដើរជូសអោយបងប្អូនថារស់ស្រួលណាស់ មិនដូចឥឡូវពិបាកណាស់៕

ក៖ ចាស ចឹងលោកយាយ នៅក្នុងក្រុមគ្រួសាររបស់លោកយាយ តើមានសមាជិកណាដែរគាត់ចេះលេងឧបករណ៍ភ្លេងខ្មែរដែរទេ?

ខ៖ អត់មានទេ ពូជខ្ញុំនិងអត់មានទេ តាម៉ុកនិងជីតាខ្ញុំត្រួចជាពូរបស់ម៉ែខ្ញុំមានតែគាត់មួយទេដែរចេះខាងភ្លេង មកដល់សម័យឥឡូវគេគិតតែខំរៀនតែឥឡូវណាថៅវាមានគំនិតចង់ឪពុកចង់យកទៅដាក់សាលាភ្លេងអោយដែរ វានិងដូចទៅមិនរួចវាអត់មានពេលវេលាណារាល់ថ្ងៃនិងវាមួយឆ្នាំបង់ជាងមួយពាន់ណំដោយកូនគេ រៀននៅសលាបេលធី ប៊ែលធីនិងវាមានប្រាំពីរសាខាចូលគ្នាទាំងអស់ វាប្រាប់ខ្ញុំថាបើវារៀននៅតែជាប់លេខមួយ កាលណាដល់អាយុប៉ុន្មានទេខ្ញុំភ្លេចហើយរៀនចប់ វាត្រូវទៅរៀននៅស្វីសហើយ បើឥឡូវវាអាយុដល់ឆ្នាំកោនិងវាអាយុដប់បីឆ្នាំហើយ ឥឡូវនិងវារៀនបានត្រឹមថ្នាក់ទីប្រាំមួយហើយ៕

ក៖ លោកយាយ តើផ្ទះរបស់លោកយាយកាលពីសម័យមុននិងមានលក្ខណះបែបណាដែរលោកយាយ?

ខ៖ ផ្ទះបុរាណ ផ្ទះចឹងណាដល់ច្រាំងបាក់ទៅ រួចទៅវាពុកវាអីទៅណានៅបងខ្ញុំមួយនិង៕

ក៖ ចុះមកដល់ឥឡូវនិង ផ្ទះយ៉ាងម៉េចដែរទៅលោកយាយ?

ខ៖ ផ្ទះឥឡូវអត់សូវមានបុរាណទេ គេរុះអស់ហើយនៅផ្ទះនេះមួយផ្ទះនេះមួយណា នេះផ្ទះបុរាណប៉ុនគ្រាន់តែកែគន់តិចតួចទេ ផ្ទះច្រើនតែផ្ទះប៊ុតចឹងណា មានសំយ៉ាបផ្ទះនៅពីមុខចឹងណា៕

ក៖ នៅពេលដែរលោកយាយនៅក្មេង តើលោកយាយធ្លាប់មានក្ដីស្រមៃមួយនៅពេលធំឡើងដែរទេ?

ខ៖ ខ្ញុំណាកាលពីមុនខ្ញុំថា រៀនអោយចប់ទៅខ្ញុំធ្វើប៉ូលីសចូលចិត្តតែលោតហោះអញ្ចឹងទៅណា គ្រូប្រាប់ពួកខ្ញុំអញ្ចេះហែងកុំឆោតពេកណា សក់និងកុំកាត់ហែងរៀនបួងចឹងទៅណា

ដល់ទៅរៀនបួងទៅហែងកាលណាហែងមានប្ដីណាបេលប្ដីវ៉យហែង ហែងអង្គុយចោង ហោងទៅហែងទាត់ពងវាទៅគ្រូនិងខូចទៀតណា ចេះតែនាំគ្នាស្ដាប់ទៅសើចទៅ៕

ក៖ ចាស ចឹងក្ដីស្រមៃរបស់លោកយាយ ចង់ធ្វើជាប៉ូលីស?

ខ៖ ចាស ចង់ធ្វើជាប៉ូលីស អត់មានចេះចង់ធ្វើគ្រូធ្វើពេទ្យអីទេ ៕

ក៖ ចង់ធ្វើប៉ូលីសនិងមិនមែន ប៉ូលីសធម្មតាទេណាប៉ូលីសសុទ្ធតែលោតហោះទៀត!

ខ៖ និងលោតហោះទៀត ចង់តែធ្វើប៉ូលីសទេដូចឆ្កួតចឹង ហើយរាល់ថ្ងៃនិងអត់ហ៊ានប្រាប់កូនទេ ខ្លាចកូននិងវាសើច ចាស៕

ក៖ ចាស ចឹងតើលោកយាយមានអ្វីផ្ដាំផ្ញើរដល់កូនចៅជំនាន់ក្រោយដែរទេលោកយាយ?

ខ៖ គ្រាន់តែចង់និយាយថា ត្រូវរស់នៅដោយរឹងពឹងកុំអោយគ្រឿងញៀនចូលមកប្រឡូក ក្នុងជីវិតយើងចឹងណា តែមានគ្រឿងញៀនចៅអើយ តែយាយសំណាងចេះមានកូនអត់អីទាំងអស់ ស្រីតែមួយប្រុសបីសុទ្ធតែត្រឹមត្រូវទាំងអស់អត់មានអីទេ រាល់ថ្ងៃនិងប្រុសមួយធ្វើការនៅក្រុមហ៊ុនដែរ គេខាងគ្រប់គ្រងគណនេយ្យប្រាក់ខែជាងពីរពាន់អីដែរ អាទីពីរនោះប្រាក់ខែតិចទេប្រពន្ធធ្វើខាងគេហៅថាលក់សំបុត្រយន្តហោះហាណា កូនខ្ញុំធ្វើការខាងក្រុមហ៊ុនទេប្រាក់ខែតែប្រាំមួយរយទេ បើអាមួយទៀតកូនក្មួយទៀតប្រាក់សុទ្ធតែជាងមួយពាន់ៗទាំងអស់ អត់អីទេប៉ុន្តែនៅតែងត់សល់ចឹង ដល់ពេលសួរទៅ គ្រាន់តែកូនវាចាយមួយខែនិងប្រាំរយ ហើយខ្លួនវានិងអត់មានស្គាល់ចាយលុយទេ ដឹងតែព្រលឹមឡើងម្ដាយក្រោកពីយប់ចឹងទៅណា ដាក់ចានស្រាកអោយទៅថ្ងៃត្រង់មកផ្ទះដឹងតែ មុនទៅសាលាដឹងម៉េចទេម៉ាក់មិនបាច់ដាក់បាយអោយខ្ញុំទៅសាលាទេ បាយស្រូបភ្លៅមាន់ហើយស៊ីសុទ្ធតែអីចឹងវិញនេះវាធឹកសុទ្ធតែតែគុជតែអីចឹងទៅណាវាចាយធំដែរនិងណា យើងគ្រាន់តែពូកសរុបវាចាយអស់ប្រាំរយ ហើយកូនតែមួយទៀតអត់មានកូនច្រើនទេ៕

ក៖ ចាស ចឹងក្មួយអរគុណច្រើនដល់លោកយាយ ដែលលោកយាយបានផ្ដល់បទសម្ភាសពីជីវប្រវត្តិរបស់លោកយាយ អោយក្មួយហើយក្មួយចង់ណែនាំខ្លួនអោយលោកយាយបានស្គាល់តិច ចៅមកពីសកលវិទ្យាល័យព្រីហ្គាមយឹងហៅកាត់ថាប៊ីវ៉ាយយូវ ហើយចៅសម្ភាសនៅថ្ងៃទី១២ខែ៩ឆ្នាំ២០១៨ នៅទីនេះហៅភូមិឃុំអ្វីដែរលោកយាយ?

ខ៖ ភូមិកោះដាច់ ឃុំកោះដាច់ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ៕

ក៖ ចាស ចឹងតើលោកយាយអាចអនុញ្ញាតអោយចៅយកសម្លេងរបស់លោកយាយ ដាក់ចូកក្នុងគេហទំព័ររបស់សាលាចៅបានដែរទេលោកយាយ?

ខ៖ មានអីចៅដាក់ចុះ កុំអោយតែដាក់ចូលទូរទស្សន៍អី៕

ក៖ ចាស អរគុណច្រើនលោកយាយ៕